ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ២៧
ចុះថ្ងៃទី១៤-០១-២០១៤
សាលដីកា
លេខ៖ ៤៨ក្រV«វ»
ចុះថ្ងៃទី ០២-១០-២០១៤

# គាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរា ក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ និងបើកសវនាកា ជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១៦-៩-២០១៤ ដោយមានសមាសភាពដូចតទៅ

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៖ ២៧ / ១៤-០១-២០១៤ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ហៅ អាថៃ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ/ឥស្លាម មុខរ នៃសាទ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វ [redacted] ឪពុកឈ្មោ [redacted] «រ» ម្តាយឈ្មោះ [redacted] «រ» ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុន ធ្លាប់ជា ពន្ធនាគារចំនួន ០៨ឆ្នាំ ឃុំខ្លួនថ្ងៃទី ៣១-៣-២០១៣ ។

<u>ជាប់ចោទពីបទ៖</u> លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា និងកាន់កាប់ ឬដឹកជញ្ជូនអាវុ ដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅ មុំមុខក្រសួងការងារ រាជធានីភ្នំពេ កាលពីខែ មីនា ឆ្នាំ២០១៣បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោ តាមមាត្រា ៣៥៣ , មាត្រា ៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។



៣៥៤

២-ជនជាប់ចោទឈ្មោះ [redacted] សាវឌី ហៅ ឌី ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នក ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្ដាយឈ្មោះ [redacted] «រ» នៅលីវ ទោសពីមុន គ្មាន ឃុំខ្លួនថ្ងៃទី ៣១-៣-២០១៣ ។

៣-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ កៃ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ នេសាទ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្ដាយឈ្មោះ [redacted] «រ» នៅលីវ ទោសពីមុន គ្មាន ឃុំខ្លួនថ្ងៃទី ៣១-៣-២០១៣ ។

៤-ជនជាប់ចោទឈ្មោះ [redacted] ភារី ហៅ រី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្ដាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ទោសពីមុន គ្មាន ឃុំខ្លួនថ្ងៃទី ៣១-៣-២០១៣ ។

-មានលោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ

៥-ជនជាប់ចោទឈ្មោះ [redacted] តន្ទរ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នកប្រដាល់ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្ដាយឈ្មោះ [redacted] «រ» ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន ០២នាក់ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន ០៥ឆ្នាំ ឃុំខ្លួនថ្ងៃ ៣០-៨-២០១៣ ។

<u>ជាប់ចោទពីបទ៖</u> លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា ប្រព្រឹត្តនៅ ម្តុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែ មីនា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ , មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ាក់ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នករាំ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] «រ» ម្ដាយឈ្មោះ [redacted] «រ» នៅលីវ ទោសពីមុន គ្មាន ឃុំខ្លួនថ្ងៃទី ៣១-៣-២០១៣ ។

<u>ជាប់ចោទពីបទ៖</u> សមគំនិតក្នុងអំពើលួច មានស្ថានទម្ងន់ទោសដោយប្រើហិង្សា ប្រព្រឹត្តនៅ ម្តុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែ មីនា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩, ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែង [redacted] ទីលំនៅសព្វថ្ងៃ [redacted]



៣៥៥

[redacted] ឪពុកឈ្មោះ [redacted] «ស» ម្ដាយឈ្មោះ [redacted] «ស» ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុន គ្មាន ឃុំខ្លួនថ្ងៃ ៣១-៣-២០១៣ ។

<u>ជាប់ចោទពីបទៈ</u> ទទួលផលចោរកម្ម ប្រព្រឹត្តនៅ មុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែ មីនា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] សុខចិន ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ។

<u>ឯរឿងហេតុមានដូចតទៅៈ</u>

កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ៨យប់ ស្ថិតនៅមុំមុខក្រសួងការងារ ជនជាប់ចោទឈ្មោះ [redacted] ហ៊ឹម ហៅ អាថៃ , ឈ្មោះ [redacted] សាវឌី ហៅ ឌី ,ឈ្មោះ [redacted] ភ័ក្ដ្រ ហៅ ភ័ក្ដ្រ ,ឈ្មោះ [redacted] វណ្ណា ហៅ កៃ និងឈ្មោះ [redacted] គន្ធរ ជិះម៉ូតូចំនួនពីរគ្រឿង មួយគ្រឿងម៉ាក MIO ជារបស់ឈ្មោះ [redacted] សុវណ្ណារ័ក្ស និងមួយគ្រឿងទៀតម៉ាក C១២៥ ប្រដាប់ដោយកាំភ្លើងខ្លីម៉ាក K៥៤ ដែលជារបស់ឈ្មោះ [redacted] ហ៊ឹម ហៅ អាថៃ បានធ្វើសកម្មភាពប្លន់យកម៉ូតូមួយគ្រឿងម៉ាកអាយខុន(ICON) ពីជនរងគ្រោះជាស្ត្រី ០៣ (បី) នាក់ ដែលកំពុងធ្វើដំណើរតាមផ្លូវ ។ ក្រោយពីធ្វើសកម្មភាពប្លន់បានសម្រេចរួច បានយកម៉ូតូទៅលក់ដោយទាក់ទងទៅឈ្មោះ [redacted] រតនា ជាអន្តរការី តាមរយៈឈ្មោះ នី ហើយឈ្មោះ [redacted] រតនា បានទាក់ទងបន្តទៅឈ្មោះ មករា នៅខេត្តកំពង់ស្ពឺ ដើម្បីទិញម៉ូតូនោះ ។

-បានឃើញសាលក្រមលេខៈ ១១៦កប២«ដ» ចុះថ្ងៃទី ១៥-១១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្ដីដូចខាងក្រោមៈ

១-ផ្ដន្ទាទោសឈ្មោះ [redacted] ហ៊ឹម ហៅ អាថៃ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារសរុបកំណត់ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០,០០០(ពីរលាន)រៀល ដាក់ចូលថវិការដ្ឋ ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា និងកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅមុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្ដន្ទាទោសឈ្មោះ [redacted] សាវឌី ហៅ ឌី ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ , ឈ្មោះ [redacted] វណ្ណា ហៅ កៃ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ , ឈ្មោះ [redacted] ភ័ក្ដ្រ ហៅ ភ័ក្ដ្រ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ , ឈ្មោះ [redacted] គន្ធរ ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៤(បួន)ឆ្នាំ ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា ប្រព្រឹត្តនៅមុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-ផ្ដន្ទាទោសឈ្មោះ [redacted] សុវណ្ណារ័ក្ស ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣(បី)ឆ្នាំ ពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា ប្រព្រឹត្តនៅមុំមុខក្រសួងការងារ

រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រម ព្រហ្មទណ្ឌ ។

៤-ផ្តន្ទាទោសឈ្មោះ [redacted] រតនា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២(ពីរ)ឆ្នាំ តែទោសជាប់ពន្ធនាគារកំណត់ ០១(មួយ)ឆ្នាំ ទោសសល់ពីនេះ ត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០(បួនលាន)រៀល ដាក់ចូលថវិការដ្ឋ ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅម្តុំមុខក្រសួងការងារ រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៣៩៩, ៤០០ និងមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ។

៥-រឹបអូសវត្ថុចាប់យករួមមានៈ

-អាវុធខ្លីម៉ាក K៥៤ លេខ ៣៧៤៦ ចំនួន ០១(មួយ)ដើម ។

-បង់ចំនួន ០១(មួយ) ។

-គ្រាប់កាំភ្លើងចំនួន ០៦(ប្រាំមួយ) គ្រាប់ , សំបកគ្រាប់ចំនួន ០១(មួយ) ។

-ឧបករណ៍ប្រើប្រាស់ថ្នាំញៀន(ដប ត ទុយោ)ចំនួន ០១(មួយ) , ដែកកេះចំនួន ០៤(បួន) ។

-ម៉ូតូម៉ាក Mio ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ ១P-៩៣៣៩ លេខតួ-លេខម៉ាស៊ីន ៥០៧៥៩០ ចំនួន ០១ (មួយ)គ្រឿង ។

ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២១៣ អយដ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

៦-ប្រគល់វត្ថុចាប់យករួមមានៈ

-ស្លាកលេខម៉ូតូ ភ្នំពេញ ១BK-៧៧៦៣ ចំនួន០១(មួយ) ។

-ចង្កើរពានមុខម៉ូតូចំនួន ០១(មួយ) ។

-កញ្ចក់ម៉ូតូចំនួន ០៤(បួន) ។

-កូនសោម៉ូតូចំនួន ០១(មួយ) ។

ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខៈ ២១៣ អយដ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឲ្យទៅម្ចាស់ដើមវិញ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ហៅ អាថៃ , ឈ្មោះ [redacted] សាវឌី ហៅ ឌី , ឈ្មោះ [redacted] វណ្ណា ហៅ តៃ ,ឈ្មោះ [redacted] រ៉ាវី ហៅ វី ,ឈ្មោះ [redacted] សុវណ្ណារ៉ាក់ និងឈ្មោះ [redacted] រតនា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គន្ធរ និងជនរងគ្រោះឈ្មោះ [redacted] សុខចិន ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



៣៥៧

•សាលក្រមនេះត្រូវបានឈ្មោះ [redacted] សារឌី ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៣ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

•សាលក្រមនេះត្រូវបានឈ្មោះ [redacted] វណ្ណា ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៣ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

•សាលក្រមនេះត្រូវបានឈ្មោះ [redacted] រ៉ាវី ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៣ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

•សាលក្រមនេះត្រូវបានឈ្មោះ [redacted] ហ៊ីម ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១៣ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជំរះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម (ចូល)

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា (ចូល)

-ជនជាប់ចោទឈ្មោះ [redacted] សារឌី (ចូល)

-លោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ (ចូល)

-ជនរងគ្រោះឈ្មោះ [redacted] សុខចិន (មិនចូល)

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ថា៖ ខ្លួនទទួលយកលោក អ៊ឹម ម៉ាច ជាមេធាវីការពារសិទ្ធិឲ្យខ្លួន ខ្លួនរស់នៅផ្សារតូច ធ្លាប់ជាប់ពន្ធនាគារ ៨ឆ្នាំ ចេញមកវិញពាក់ព័ន្ធនិងរឿងចាយវាយលុយជាមួយមិត្តភក្តិ ។ ពួកខ្លួនមានឈ្មោះ [redacted] វណ្ណា , [redacted] គន្ធរ , [redacted] រ៉ាវី , សុខ សារឌី និង ខ្លួន បានឃើញស្រីៗជិះម៉ូតូបីនាក់ ពួកខ្លួនក៏ជិះកៀរ មិនបានប្រើកាំភ្លើងទេ ។ ក្រោយរយៈពេលមួយខែ ពីថ្ងៃធ្វើសកម្មភាព មានគេតេហៅខ្លួន ទើបខ្លួនដាក់កាំភ្លើងជាប់ខ្លួន ក៏ត្រូវប៉ូលីសចាប់តែម្តង ។ ខ្លួនធ្លាប់ធ្វើសកម្មភាពប្លន់ចំនួនបីដងមកហើយ ការដាក់ទោសសរុបចំនួន ៣៨ឆ្នាំ ។ សុំលោកប្រធានមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ថា៖ ខ្លួនទទួលយកលោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិឲ្យខ្លួន ខ្លួនបានធ្វើសកម្មភាពដូចពួកគេនិយាយអញ្ចឹង គឺគ្មានកាំភ្លើងទេ ហើយឈ្មោះ [redacted] សារឌី និយាយថា ខ្ញុំមិនធ្វើបាបពួកនាងទេ ខ្ញុំចង់បានតែម៉ូតូទេ កុំស្រែក ។ សុំបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ជនជាប់ចោទឈ្មោះ [redacted] សារឌី ថា៖ ខ្លួនទទួលយកលោក [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិឲ្យខ្លួន ខ្លួនជិះខាងក្រោយ ខ្លួនបានយកម៉ូតូជនរងគ្រោះទៅលក់នៅជិតថ្នល់ទទឹង បានប្រាក់ ៣០០$ ចែកគ្នាអស់ហើយ ។ សុំបន្ធូរបន្ថយទោសដល់ខ្លួនផង ។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

ជនជាប់ចោទបានឆ្លើយសារភាពពីសកម្មភាពរបស់ខ្លួន ដូច្នេះសំអាងហេតុរបស់តុលាការថ្នាក់ក្រោមមានលក្ខណៈត្រឹមត្រូវហើយ ។ សុំតម្កល់សាលក្រមលេខ ១១៦កប២«ដ» ១៥-១១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

## មេធាវីធ្វើសេចក្ដីសន្និដ្ឋាន

កូនក្ដីខ្ញុំបានសារភាពតាំងពីនគរបាលមក ហើយពួកគាត់ក៏បានទទួលស្គាល់នូវកំហុសដែរ ។ ចំពោះបញ្ហាដែលពួកគាត់ប្ដឹងឧទ្ធរណ៍ គឺគ្រាន់តែសុំឲ្យជួយបន្ធូរបន្ថយទោស ព្រោះពេលកើតហេតុ ពួកគាត់មិនបានប្រើប្រាសអាវុធទេ អាវុធនេះកើតនៅអង្គហេតុផ្សេងទៀត ។ សុំលោកប្រធានមេត្តាបន្ធូរបន្ថយទោសដល់ពួកគាត់ផង ។

## តុលាការថយទៅពិភាក្សា

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្ដាប់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន។

-ក្រោយពីបានស្ដាប់សំណូមពររបស់ជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា៖

១/បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២២-១១-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១១-១២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា , ជនជាប់ចោទឈ្មោះ [redacted] ភ៉ារី និងបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-១២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សាវឌី ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ១១៦ កប២«ដ» ចុះថ្ងៃទី ១៥-១១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំនត់ច្បាប់ យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២/តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលឃើញថា៖ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម, ឈ្មោះ [redacted] សាវឌី, ឈ្មោះ [redacted] ភ៉ារី ,ឈ្មោះ [redacted] វណ្ណា និងគូកនពិតជាបានធ្វើសកម្មភាពប្លន់យកម៉ូតូម៉ាកអាយខុន(ICON) ពីជនរងគ្រោះ ដែលកំពុងធ្វើដំណើរតាមផ្លូវដោយឈ្មោះ [redacted] ហ៊ីម ប្រដាប់ដោយអាវុធខ្លីម៉ាក K54 មួយដើមប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា និងកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ចំពោះជនជាប់ចោទឈ្មោះ [redacted] ហ៊ីម និងបទ៖ លួចមានស្ថានទម្ងន់ទោសដោយប្រើហិង្សា ចំពោះជនជាប់ចោទឈ្មោះ [redacted] សាវឌី , ឈ្មោះ [redacted] ភ៉ារី និងឈ្មោះ [redacted] វណ្ណា តាមបញ្ញត្តិនៃមាត្រា ៣៥៣, មាត្រា ៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌដូចមានខ្លឹមសារក្នុងផ្នែកសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ស្រាប់ ហើយដែលសាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុទាំងនោះ ។ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៣/សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍៖ ឆ្លងតាមការសួរដេញដោលឃើញថា៖ ជនជាប់ចោទទាំងអស់នេះ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូចនេះសុំឲ្យសាលាឧទ្ធរណ៍

តម្កល់សាលក្រមសាលាដំបូងទុកជាបានការ ។ ឃើញថា៖ សេចក្តីសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសាលាឧទ្ធរណ៍ពិចារណា និងសម្រេច ។

៤/មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក៏ដូចជាជនជាប់ចោទដែរ បានសំណូមពរ សុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស ។ ចំណុចនេះ សាលាឧទ្ធរណ៍យល់ឃើញថា៖ ទោសដែលសាលាដំបូងបានប្រកាសទៅលើជនជាប់ចោទម្នាក់ៗ គឺមានលក្ខណៈសមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជនជាប់ចោទ ហើយ ដូចនេះ សាលាឧទ្ធរណ៍មិនពិចារណាពីសំណូមពរនេះឡើយ ។

៥/សាលក្រមព្រហ្មទណ្ឌលេខ៖ ១១៦កប២«ដ» ចុះថ្ងៃទី ១៥-១១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២-១១-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម , បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១១-១២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា , ជនជាប់ចោទឈ្មោះ [redacted] រ៉ និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣-១២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សាវឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់ ។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៖ ១១៦កប២«ដ» ចុះថ្ងៃទី ១៥-១១-២០១៣ របស់សាលាដំបូ រាជធានីភ្នំពេញ ទុកជាបានការ ។

៣/បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

-សាលដីកានេះ ជំនុំជំរះជាសាធារណៈថ្ងៃទី ១៦-៩-២០១៤ និងប្រកាសជាសាធារណៈថ្ងៃទី ០២-១០-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ,ឈ្មោះ [redacted] សាវឌី និងឈ្មោះ [redacted] ណ្ណា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រ៉ាវី ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**សាលដីកានេះបានចូលជាស្ថាពរចំពោះឈ្មោះ [redacted] ហ៊ីម ,ឈ្មោះ [redacted] សាវឌី និងឈ្មោះ [redacted] វណ្ណា រីឯឈ្មោះ [redacted] រ៉ាវី នៅមិនទាន់ចូលជាស្ថាពរនៅឡើយ ។**

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] , [redacted] | ហត្ថលេខា៖ [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១(

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍